សលាកប័ត្រព័ត៌មាន NEWSLETTER
លេខ: ៥០ ខែមេសា-ឧសភា ឆ្នាំ២០១០
Issue: 50 April-May 2010

ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# វេទិកាសាធារណៈនៅអន្លង់វែង: យុត្តិធម៌ និង ការបង្រួបបង្រួម

## *Public Forum in Anlong Veng: Justice and Reconciliation*

កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ កន្លងទៅនេះ វេទិកាសាធារណៈ ស្តីពី "*ការចូលរួមរបស់ជនរងគ្រោះ : ប្រែក្លាយវាល ពិឃាតឱ្យទៅជាកន្លែងផ្សះផ្សា និងរួមរស់ជាមួយគ្នា*" ត្រូវបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយ មានឈ្មោះថា *មជ្ឈមណ្ឌល ដើម្បីយុត្តិធម៌ និងការបង្រួមបង្រួម* នៅឯទីធ្លាផ្ទះតាម៉ុក នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលធ្លាប់ជាសមរភូមិចុងក្រោយរបស់ក្រុមខ្មែរក្រហម។



*អ្នកចូលរួមវេទិកាសាធារណៈ នៅអន្លង់វែង ផ្ទះតាម៉ុក*

នៅក្នុងចំណោមអ្នកចូលរួមប្រមាណ១០០នាក់ ដែលបានអញ្ជើញមកពីភូមិ ឃុំ ផ្សេងៗ នៃស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលភាគច្រើនសុទ្ធសឹងតែជាអតីតខ្មែរក្រហម ក៏មានអ្នកចូលរួមខ្លះទៀត ជាជនរងគ្រោះនៃរបបខ្មែរក្រហមផងដែរ ដែលធ្វើឱ្យវេទិកានេះកាន់តែមានសារៈសំខាន់ក្នុងការផ្តួចផ្តើមនូវកិច្ចពិភាក្សាគ្នាអំពីរឿងរ៉ាវអតីតកាល ប្រយោជន៍ដើម្បីជំរុញឱ្យមានការផ្សះផ្សាខាងផ្លូវចិត្តរបស់ភាគីទាំងពីរ នៅខណៈពេលដែលកំពុងតែមានកិច្ចដំណើរការស្វែងរក យុត្តិធម៌ជូនជនរងគ្រោះជាច្រើន ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

លោក **អ៊ឹម សុភា** និង លោក **សេខ តារាវុធ** ដែលជាសហនាយកនៃមជ្ឈមណ្ឌលដើម្បីយុត្តិធម៌ និងការផ្សះផ្សានេះ សុទ្ធតែបានសំដែងនូវសុទិដ្ឋិនិយមថា វេទិកាពិភាក្សាអំពីការផ្សះផ្សា និងយុត្តិធម៌ ដែលបានរៀបចំធ្វើឡើងនៅទីធ្លាប្រវត្តិសាស្ត្រផ្ទះតាម៉ុកនេះ បានបង្កើតឱកាសឱ្យមានកិច្ចពិភាក្សារវាងជនរងគ្រោះ និងអតីតជនដែលដល់ខ្មែរក្រហម ក្នុងការបង្ហាញនូវទឹកចិត្ត ក៏ដូចជារឿងរ៉ាវអតីតកាលក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលគេបានឆ្លងកាត់ចំពោះគ្នាទៅវិញទៅមក។ បើទោះបីជាតាមរយៈវេទិកា ដែលមានរយៈពេលតែ ១ ថ្ងៃនេះ មិនអាចឱ្យដោះស្រាយបញ្ហានៅក្នុងចិត្តរបស់ភាគីទាំងពីរបាន ពិតមែន ប៉ុន្តែវាជាការចាប់ផ្តើមដ៏សំខាន់ និងកម្រមួយ។

នៅក្នុងវេទិកានេះ ក៏មានវត្តមានរបស់តំណាងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋានផងដែរ ដើម្បីជួយឆ្លើយតបនូវចំណោទបញ្ហា ឬការមន្ទិលផ្សេងៗរបស់អ្នកចូលរួម។ អ្នកចូលរួមស្ទើរតែទាំងអស់សុទ្ធតែបានបង្ហាញនូវទឹកចិត្តចង់ចូលរួមស្តាប់ដោយផ្ទាល់នូវដំណើរការវិវត្តន៍ នៃការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ក៏ដូចជាការផ្សះផ្សាបង្រួបបង្រួម ចំពោះរឿងរ៉ាវឧក្រិដ្ឋកម្មកាលពីអតីតកាល ក្នុងទិសដៅឆ្ពោះទៅរកការរួមរស់ជាមួយគ្នាដោយសុខសាន្ត។

នៅក្នុងឱកាសនោះដែរ មន្ត្រីសាលាក្តី លោក **ឡាស អូល សុន** ក៏បានផ្តល់ជូននូវព័ត៌មានស្តីពីដំណើរការជំនុំជម្រះនៃសំណុំរឿង ០០១ ដែលមាន **លោក កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ជាជនជាប់ចោទ ហើយ ដែលទើបតែត្រូវបានអង្គជំនុំជម្រះសាលាដំបូងបញ្ចប់ការកាត់សេចក្តីរួចហើយ និងរង់ចាំតែការប្រកាសសាលក្រមប៉ុណ្ណោះ។ ចំណែកឯ សំណុំរឿង ០០២ ដែលមានជនត្រូវចោទចំនួន ៥រូប សំខាន់ៗ គឺ **លោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន លោកស្រី អៀង ធីរិទ្ធ** និង **លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច** ក៏កំពុងត្រូវបានសហចៅក្រមស៊ើបអង្កេតពិនិត្យ និងកសាងសំណុំរឿង ហើយអាចនឹងត្រូវបានបញ្ជូនទៅជំនុំជម្រះ នៅក្រោយពេលដែលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ដែលអាចនឹងត្រូវបានចេញនៅអំឡុង ខែកញ្ញាខាងមុខនេះ។ ដោយឡែកសំណុំរឿង០០៣ និង០០៤ ដែលមាន

ជនសង្ស័យបន្ថែមផ្សេងទៀត ហើយដែលត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិសំរេចចោទប្រកាន់ ដោយមានការគាំទ្រ ដោយអង្គបុរេជំនុំជម្រះនោះ ក៏ត្រូវបានបញ្ជូនទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតរួចហើយ និងរង់ចាំតែចំណាត់ការបន្ទាប់ទៀតពីសំណាក់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ។ ចំពោះសំណុំរឿងចោទប្រកាន់បន្ថែមនេះ ក៏ធ្វើឱ្យមានការចាប់អារម្មណ៍ច្រើននៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ថ្នាក់ដឹកនាំ នៃរាជរដ្ឋាភិបាលប្រទេសកម្ពុជា និងអតីតកម្មាភិបាលខ្មែរក្រហម ដោយសារតែគេមានការព្រួយបារម្ភថា វាអាចធ្វើឱ្យកើតមាននូវអស្ថិរភាពសង្គម។ ប៉ុន្តែទោះបីជាមានការលើកឡើងយ៉ាងដូចនេះក៏ដោយក៏មានអ្នកចូលរួមវេទិកាខ្លះផ្សេងទៀតយល់ថា យុត្តិធមិពិតប្រាកដមិនមែនត្រឹមតែការកាត់ទោសមេដឹកនាំ៥រូប ដែលកំពុងត្រូវបានដាក់ឱ្យស្ថិតនៅក្នុងការឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញនេះទេ គឺថា វាស្ថិតទៅលើសមត្ថកិច្ចរបស់តុលាការនេះផ្ទាល់ នៅក្នុងការស្វែងរកយុត្តិធមិជូនជនរងគ្រោះបានដល់កំរិតណា។

ថ្វីត្បិតតែ មានការសំដែងឡើងនូវមតិចាប់អារម្មណ៍ផ្សេងៗ អំពីការកាត់សេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការផ្សះផ្សាបង្រួបបង្រួមនៅក្នុងចំណោមអ្នកចូលរួម ក៏ប៉ុន្តែវេទិកាប្រភេទនេះទើបតែមានជាលើកដំបូង នៅក្នុងអតីតទីតាំងប្រយុទ្ធចុងក្រោយរបស់ខ្មែរក្រហម ដែលបានផ្តល់ឱកាសឱ្យមានការចូលរួម និងការទទួលយកនូវព័ត៌មានអំពីដំណើរការនេះ។ អ្នកចូលរួមវ័យក្មេងជំនាន់ក្រោយ បានសំដែងនូវចំណាប់អារម្មណ៍អំពីការចង់ដឹងនូវការពិត អំពីរឿងរ៉ាវឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបខ្មែរក្រហម ហើយក៏បានសំណូមពរឱ្យថែរក្សានូវប្រវត្តិសាស្ត្រនេះទុក សម្រាប់អ្នកជំនាន់ក្រោយទៀតដើម្បីឱ្យគេបានរៀនសូត្រ ដឹងឮ និងចងចាំ ព្រមទាំងរួមគ្នាកសាងសង្គមកម្ពុជា ឱ្យឆ្ពោះទៅកាន់សន្តិភាព និងការផ្សះផ្សាបង្រួបបង្រួមយ៉ាងពិតប្រាកដ។

## សង្គមស៊ីវិលអំពាវនាវឱ្យមានដំណើរការឆ្ពោះទៅមុខ និងឯករាជ្យភាពរបស់សាលាក្តីខ្មែរក្រហម

## Civil Society Calls for ECCC's Move and Judicial Independence

នៅក្នុងដំណើរទស្សនកិច្ច របស់មន្ត្រីជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ គឺ លោកស្រី **ប៉ាទ្រីស្យា អូប្រាយអែន** (Patricia O' Brien) ដែលជាអគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ មកកាន់ព្រះរាជាណាចក្រកម្ពុជា ដើម្បីជួបពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា, មន្ត្រីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតំណាងអង្គការសង្គមស៊ីវិល ដែលបានធ្វើការយ៉ាងជិតស្និទ្ធពាក់ព័ន្ធនឹងសាលាក្តីខ្មែរក្រហម កាលពីចុងខែមេសា ឆ្នាំ ២០១០ បានបង្កើតឱ្យមានលំហនៃកិច្ចពិភាក្សាជាវិជ្ជមានមួយ។

ជាក់ស្តែង នៅក្នុងជំនួបជាមួយនឹងតំណាងអង្គការសង្គមស៊ីវិល លោកស្រីបានសំដែងនូវការអបអរសាទរចំពោះ ចំណុចវិជ្ជមានជាច្រើន ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហមសម្រេចបាន ចាប់តាំងពីចាប់ផ្តើមដំណើរការតាំងពីឆ្នាំ២០០៦ ដោយរាប់បញ្ចូលទាំងការបើកសវនាការកាត់សេចក្តីអតីតប្រធានមន្ទីរ ស-២១ ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** និងចំណាត់ការផ្លូវច្បាប់ជាបន្តបន្ទាប់ទៅលើសំណុំរឿងអតីតមេដឹកនាំ៤រូបទៀត គឺ: **លោក ខៀវ សំផន, លោក នួន ជា, លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ** ដែលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងមន្ទីរឃុំខ្លួនបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ និងរង់ចាំការបញ្ជូនខ្លួនទៅកាត់ទោសនៅឆ្នាំខាងមុខ។

ប៉ុន្តែទន្ទឹមនឹងការសំដែងនូវការអបអរសាទរ ទៅលើចំណុចវិវត្តន៍ជាវិជ្ជមាននេះ តំណាងសង្គមស៊ីវិលក៏សំដែងនូវការព្រួយបារម្ភ និងអំពាវនាវស្នើដល់លោកស្រីអគ្គលេខាធិការរងឱ្យបន្តសហការចាត់វិធានការបន្ទាន់ថែមទៀតជាមួយសមភាគីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានាឱ្យបាននូវដំណើរការឆ្ពោះទៅមុខរបស់សាលាក្តីខ្មែរក្រហមប្រកបដោយឯករាជ្យ និងជោគជ័យ។ ក្នុងនោះ តំណាងសង្គមស៊ីវិល បានអំពាវនាវឱ្យមានការយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗមួយចំនួន ដូចខាងក្រោមនេះ :

ទី១- *ប្រក្រតីភាព និងថវិកា* សម្រាប់ប្រតិបត្តិការរបស់សាលាក្តីឱ្យបានគ្រប់គ្រាន់ ជាពិសេសនៅតំណាក់កាលដែលសំណុំរឿង ០០២ កំពុងតែឈានដល់តំណាក់កាលសំខាន់ ឈានឆ្ពោះទៅការកាត់សេចក្តីនៅឆ្នាំខាងមុខ។ ការផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា គឺនឹងជួយដល់ដំណើរការឆ្ពោះទៅមុខរបស់សាលាក្តីខ្មែរក្រហម ក្នុងការសម្រេចឱ្យបាននូវបេសកកម្មរបស់ខ្លួន ដើម្បីស្វែងរកយុត្តិធមិជូនដល់ជនរងគ្រោះ និងប្រជាជាតិកម្ពុជា ដែលបានទន្ទឹងរង់ចាំជាយូរមកហើយ។

ទី២- ការតែងតាំងជាបន្ទាន់នូវ *ទីប្រឹក្សាពិសេស* ដែលជាអ្នកទទួលបន្ទុកការងារដ៏សំខាន់របស់សាលាក្តី ជាពិសេសសម្រាប់ធានានូវប្រក្រតីភាព និងនិរន្តរភាពនៃការងាររបស់សាលាក្តី ក៏ដូចជាសម្របសម្រួល ទៅលើកិច្ចការដ៏សំខាន់ៗរបស់សាលា

ក្តីនេះផងដែរ។ ជាការពិតដើម្បីឱ្យមានការតែងតាំងនូវអ្នកដែលមានតួនាទីដ៏សំខាន់នេះ ទាមទារឱ្យមានពេលវេលាគ្រប់គ្រាន់ និងត្រឹមត្រូវ គឺថា ពេលវេលាបច្ចុប្បន្ននេះ គឺជាពេលវេលាសមស្របហើយ សម្រាប់ចាប់ផ្តើមដំណើរការនេះ ដើម្បីធានាថា ទីប្រឹក្សាពិសេសនឹងអាចជួយសម្របសម្រួល ក៏ដូចជាចរចាជាបន្តបន្ទាប់រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទៅលើបញ្ហាសំខាន់ៗ ដែលកំពុងតែមាននៅចំពោះមុខសាលាក្តីខ្មែរក្រហមនេះ ជាពិសេស គឺការជំរុញឱ្យមានការការចាប់ផ្តើមបើកការស៊ើបអង្កេតទៅលើសំណុំរឿងផ្សេងទៀតក្រៅពីសំណុំរឿង០០១ និង ០០២ ដែលត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះ ហើយដែលបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអន្តរជាតិបន្តនីតិវិធីបញ្ជូនដីកាស៊ើបអង្កេតបឋម ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត កាលពីឆ្នាំមុនកន្លងមកនោះ។

ទី៣- ការចរចារវាងអង្គការសហប្រជាជាតិ ម្ចាស់ជំនួយនានា និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតឱ្យបាននូវ*យុទ្ធសាស្ត្រ*ច្បាស់លាស់ សម្រាប់ការបញ្ចប់បេសកកម្មរបស់សាលាក្តីខ្មែរក្រហម គឺជាទិសដៅសំខាន់មួយ ដែលអាចជួយធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់ ជាពិសេសជនរងគ្រោះ ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការព្រហ្មទណ្ឌរបស់តុលាការនេះ ព្រមទាំងសហគមន៍អន្តរជាតិដទៃទៀត ឱ្យកាន់តែមានជំនឿទុកចិត្តទៅលើដំណើរការនៃការកាត់សេចក្តីនេះ និងលែងមានមន្ទិលសង្ស័យអំពីឆន្ទៈនយោបាយផ្សេងៗផងដែរ។ ប្រសិនបើត្រូវបានបង្កើតឡើងតាមរយៈការឯកភាពគ្នា ដោយភាគីទាំងបីនេះ នោះយុទ្ធសាស្ត្រនេះក៏នឹងអាចជួយចង្អុលបង្ហាញឱ្យកាន់តែច្បាស់លាស់នូវទិសដៅពិតប្រាកដ របស់សាលាក្តីខ្មែរក្រហម ក្នុងការបំពេញ បេសកកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងក៏អាចជួយកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាន ដែលអាចគំរាមកំហែងទៅលើឯករាជ្យភាព និងកិច្ចដំណើរការកាត់សេចក្តីដោយយុត្តិធម៌ផងដែរ។

គួរបញ្ជាក់ថា សំណូមពររបស់តំណាងអង្គការសង្គមស៊ីវិលទាំងនេះបានធ្វើឡើង ក្រោយពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយ ដែលបានគូសបញ្ជាក់អំពីភាពសុទិដ្ឋិនិយមចំពោះកិច្ចសហប្រតិបត្តិការល្អរវាងភាគីទាំងពីរក្នុងការបន្តការគាំទ្រដំណើរការទៅមុខ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សេចក្តីថ្លែងការណ៍នេះ ត្រូវបានធ្វើឡើងក្រោយពីមានជំនួបផ្លូវការរវាងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាគឺ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** និង លោកស្រី **ប៉ាទ្រីស្យា អូប្រាយ អែន** អគ្គលេខាធិការរងអង្គការសហប្រជាជាតិ។

នៅក្នុងសេចក្តីប្រកាសព័ត៌មានរួមគ្នា ដែលបានចេញផ្សាយកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០១០ បានគូសបញ្ជាក់ថា: *"ទាំងភាគីរាជរដ្ឋាភិបាលកម្ពុជា និងភាគីអង្គការសហប្រជាជាតិប្តេជ្ញាបញ្ចប់នូវនីទណ្ឌភាពចំពោះសោកនាដកម្មនៃរបបខ្មែរក្រហម ហើយគាំទ្រ និងគោរពយ៉ាងពេញលេញដល់អង្គជំនុំជម្រះវិសាមញ្ញ និងឯករាជ្យភាពនៃដំណើរការផ្លូវច្បាប់របស់សាលាក្តីនេះផងដែរ។"* សេចក្តីថ្លែងការណ៍ដដែលនេះ ក៏បានគូសបញ្ជាក់នូវការប្តេជ្ញាចិត្តថែមទៀតរបស់ភាគីទាំងពីរក្នុងការអំពាវនាវ សុំឱ្យមានការផ្តល់ថវិកាបន្ថែមដល់សាលាក្តីនេះ ដើម្បីឱ្យបំពេញប្រតិបត្តិការបានពេញលេញ និងទៅមុខជាបន្តបន្ទាប់។

## អង្គបុរេជំនុំជម្រះប្រកាសបដិសេធ ការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់ជនត្រូវចោទ

### ECCC Pre-Trial Chamber Announces Decisions on Pre-Trial Detention Appeals by Charged Persons

អង្គបុរេជំនុំជម្រះ នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសដោយឡែកៗពីគ្នា នូវសាលដីកាបណ្តឹងឧទ្ធរណ៍បដិសេធការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់ជនត្រូវចោទដែល ជាអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ គឺ **លោក អៀង សារី, លោក ខៀវ សំផន និងលោកស្រី អៀង ធីរិទ្ធ** កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ កន្លងទៅនេះ។

គួររំលឹកថា ជនត្រូវចោទទាំងបីរូបនេះ បានធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន១ឆ្នាំទៀត ដែលជាឆ្នាំទី៣ នៃការដាក់ឱ្យស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅមន្ទីរឃុំខ្លួនរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលសម្រេចធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។ សវនាការទៅលើបណ្តឹងឧទ្ធរណ៍សម្រាប់ជនត្រូវចោទទាំងបីនៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវបានប្រព្រឹត្ត



*អៀង សារី*



*ខៀវ សំផន*



*អៀង ធីរិទ្ធ*

ទៅជាបន្តបន្ទាប់គ្នា គឺកាលពីថ្ងៃទី១១, ១២ និង ១៥ ខែកុម្ភៈ ឆ្នាំ២០១០ កន្លងទៅនេះ។

លើកនេះ គឺជាលើកចុងក្រោយហើយ ដែលអង្គបុរេជំនុំជម្រះ បានចេញសាលដីកាបដិសេធសំណើសុំនៅក្រៅឃុំបណ្តោះ

អាសន្នរបស់ជនត្រូវចោទទាំងបីរូប ដោយអង្គបុរេជំនុំជម្រះយល់ឃើញថា *ការដាក់បន្តថេរវេលាឃុំបណ្តោះអាសន្នជនត្រូវចោទ គឺជាវិធានការចាំបាច់ សម្រាប់ធានាកិច្ចដំណើរការទៅមុខរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធានាទូវវត្តមានរបស់ជនត្រូវចោទទាំងបី ក៏ដូចជា ដើម្បីការពារសុវត្ថិភាពរបស់គេផ្ទាល់ ព្រមទាំងការពារកុំឱ្យមានការបំផ្លាញភស្តុតាង និងគំរាមកំហែងសាក្សី និងជនរងគ្រោះផងដែរ។*

ជនត្រូវចោទទាំងបីនាក់នេះ ត្រូវបានសហចៅក្រមស៊ើបអង្កេតចោទប្រកាន់ពី *បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម, អំពើមនុស្សឃាត, ទារុណកម្ម និងអំពើធ្វើទុក្ខបុកម្នេញខាងសាសនា* នៅក្នុងរយៈកាលដែលខ្លួនបានកាន់អំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបច្ចុប្បន្នកំពុងតែរង់ចាំការបញ្ជូនខ្លួនទៅកាត់សេចក្តីដោយអង្គជំនុំជម្រះសាលាដំបូង នៅក្រោយពេលដែលសហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយ ដើម្បីបញ្ជូនទៅជំនុំជម្រះនៅពេលខាងមុខនេះ។ ជនត្រូវចោទទាំងបីនេះ សុទ្ធតែត្រូវបានសហចៅក្រមស៊ើបអង្កេតដាក់ឱ្យស្ថិតនៅក្នុងសំណុំរឿង០០២ ជាមួយនឹងលោក **នួន ជា** និង លោក **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** (សំណុំរឿង០០១ ផង និងកំពុងរង់ចាំការប្រកាសសាលក្រម)។

**ជនត្រូវចោទ អៀង សារី**

ជនត្រូវចោទ **អៀង សារី** ហៅ **វ៉ាន់** ធ្លាប់ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញចាប់ខ្លួន និងដាក់ឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧។ ដូចនេះ ការបន្តរយៈពេលឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទនេះ គឺ រហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ខាងមុខ លើកលែងតែសហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយមុនកាលបរិច្ឆេទនេះ។

លោក អៀង សារី កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿងវ៉ា ឃុំលឿងវ៉ា ខេត្តត្រាវិញប្រទេសវៀតណាម។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោក គឺជាសមាជិកជាន់ខ្ពស់ម្នាក់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ បច្ចុប្បន្ន ជនត្រូវចោទមានមេធាវីពីររូបការពារក្តី គឺលោកមេធាវី **អាង ឧត្តម** និងលោកមេធាវី **ម៉ៃឃើល ការណាវ៉ាស** (ជនជាតិអាមេរិក)។

**ជនត្រូវចោទ ខៀវ សំផន**

ជនត្រូវចោទ **ខៀវ សំផន** ហៅ **ហែម** ធ្លាប់ជាប្រមុខរដ្ឋ ឬប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។ ការបន្តរយៈពេលឃុំខ្លួនបណ្តោះអាសន្នតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើជនត្រូវចោទ **ខៀវ សំផន** នឹងពន្យាររហូតដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ លើកលែងតែសហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយមុនកាលបរិច្ឆេទនេះ។

លោក **ខៀវ សំផន** កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅខេត្តស្វាយរៀង។ សហមេធាវីពីររូបកំពុងការពារក្តីឱ្យលោក គឺលោកមេធាវី **ស សុវាន** និងលោកមេធាវី **ហ្សាក វែរហ្សេស** (ជនជាតិបារាំង)។

**ជនត្រូវចោទ អៀង ធីរិទ្ធ**

ជនត្រូវចោទ**អៀង ធីរិទ្ធ** គឺជាសមាជិកជាន់ខ្ពស់ម្នាក់នៅក្នុងរបបខ្មែរក្រហម ដែលកាន់តួនាទីជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច។ លោកស្រី គឺជាភរិយារបស់លោក **អៀង សារី**។ ជនត្រូវចោទរូបនេះ ត្រូវបាន អង្គជំនុំជម្រះវិសាមញ្ញ ចាប់ខ្លួន និងឃុំខ្លួន នៅថ្ងៃជាមួយគ្នានឹងស្វាមីរបស់លោកស្រី គឺនៅថ្ងៃ ទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧។ តាមការសម្រេចរបស់អង្គបុរេជំនុំជម្រះលើកនេះ ការបន្តរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ទៅលើជនត្រូវចោទរូបនេះ គឺរហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ លើកលែងតែ សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយមុនកាលបរិច្ឆេទនេះ។

លោកស្រី អៀង ធីរិទ្ធ កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣១ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ។ លោកស្រីមានមេធាវីការពារក្តីចំនួនពីររូប គឺ លោកមេធាវី **ផាត់ ពៅស៊ាង** និងលោកស្រីមេធាវី **ដាយអាណា អេលីស** (ជនជាតិអង់គ្លេស)។

**អានុភាពនៃដីកាដំណោះស្រាយ:**

ប្រសិនបើសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយមុនកាលបរិច្ឆេទឃុំខ្លួនបណ្តោះអាសន្នខាងលើនោះ ដីកានេះនឹងនាំមកនូវការបញ្ចប់ថេរវេលាខាងលើទាំងនេះបាន។

**ព័ត៌មានសំខាន់:**

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ ហើយចង់សាកសួរព័ត៌មានអំពីសាលាក្តីខ្មែរក្រហមបន្ថែមទៀត

**សូមទាក់ទង:**

- អង្គភាពគាំពារជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១
- ការិយាល័យកិច្ចការសាធារណៈ: លេខទូរស័ព្ទ: ០១២ ៤៨៨ ១៥៦

➢ ស្តាប់ *កម្មវិធីឃ្លាំមើលសាលាក្តី* ដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញ តាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។

➢ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ **www.krtrial.info**

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ ឌី.អ៊ី.ឌី(DED) និង អូ.អេស.ជេ.អាយ(OSJI)ទេ។*

**ឧបត្ថម្ភមូលនិធិដោយ: ឌី.អ៊ី.ឌី និង អូ.អេស.ជេ.អាយ**